CITY OF LONG BEACH

សាលាក្រុងឡុងប៊ីឆ
ការិយាល័យព័ត៌មានសាធារណៈ
411 W. Ocean Blvd,
Long Beach, CA 90802

# សេចក្តីប្រកាសព័ត៌មាន

**4/3/2020**

សំរាប់ផ្សព្វផ្សាយបន្ទាន់

សេចក្តីប្រកាសព័ត៌មាន # 040320B

**ប្រធានបទ:** **សាលាក្រុងឡុងប៊ីឆ រៀបចំសំរាប់លំហូរចូលយ៉ាងច្រើននៃឯកត្តជនស្វះស្វែងរកការថែទាំវេជ្ជសាស្ត្រ**
វិធានការណ៍ចំរុះផ្សេងៗបានត្រូវអនុវត្ត ដើម្បីកាត់បន្ថយនូវសម្ពាធលើមន្ទីរពេទ្យ ដើម្បីឆ្លើយតបទៅនិងជំងឺ COVID-19

**ទំនាក់ទំនង:** មជ្ឈមណ្ឌលព័ត៌មានរួម សាលាក្រុងឡុងប៊ីឆ
562.570.NEWS
jic@longbeach.gov

ក្រុងឡុងប៊ីឆ, រដ្ឋកាលីហ្វ័រញ៉ា - សាលាក្រុងឡុងប៊ីឆ កំពុងចាត់វិធានការណ៍ផ្សេងៗយ៉ាងទូលំទូលាយ ក្នុងការរៀបចំសំរាប់លំហូរចូលយ៉ាងច្រើននៃឯកត្តបុគ្គលដែលស្វះស្វែងរកការថែទាំវេជ្ជសាស្ត្រ ដើម្បីឆ្លើយតបទៅនិងជំងឺ COVID-19, រួមមាន ទាំងការបង្កើតនូវមន្ទីរពេទ្យតង់ចល័ត, ការបើកនូវគ្លីនិកប៉ាន់ប្រមាណឆាប់រហ័សដោយឥតគឺតថ្លៃ និងការរៀបចំមន្ទីរពេទ្យតាមទីធ្លាកីឡា។  ស៊ីធីកំពុងរៀបចំបង្កើតនូវវិធានការណ៍យ៉ាងហ្មត់ចត់គ្រប់ប្រភេទទាំងអស់នេះ ក្នុងព្រឹត្តិការណ៍ដែលមានតំរូវការជំរើសចំលាស់នានានៃវេជ្ជសាស្ត្រ ដើម្បីធ្វើការព្យាបាល ការកើនឡើងនៃអ្នកជំងឺវេជ្ជសាស្ត្រយ៉ាងឆាប់រហ័ស នៅក្នុងស៊ីធី។

អភិបាលក្រុង Robert Garcia មានប្រសាសន៍ថា “យើងធ្វើអ្វីៗគ្រប់បែបយ៉ាងក្នុងអំណាចរបស់យើង ដើម្បីរៀបចំសំរាប់ការកើនឡើងយ៉ាងឆាប់រហ័សនៃវេជ្ជសាស្ត្រ និងមន្ទីរពេទ្យ នៅប៉ុន្មានអាទិត្យខាងមុខនេះ,”។  “យើងបានបន្ថែមនូវចំណុះឬសមត្ថភាពមន្ទីរពេទ្យ និងគ្លីនិក ដោយមានរាប់រយគ្រែ ហើយយើងនិងធ្វើដូច្នេះបន្តទៀត”។

មន្ទីរពេទ្យតង់ចល័តនានា បានត្រូវបង្កើតឡើងខាងក្រៅបន្ទប់សង្គ្រោះបន្ទាន់ នៅឯ Long Beach Memorial Medical Center, St. Mary Medical Center និង College Hospital ហើយកំពុងផ្តល់នូវការប៉ាន់ប្រមាណវេជ្ជសាស្ត្រ និងធ្វើការចំណាត់ថ្នាក់ជាក្រុម ដល់ឯកត្តបុគ្គល ដែលបង្ហាញនូវរោគសញ្ញាស្រាល ទៅដល់មធ្យម នៃជំងឺ COVID-19។ ក្រសួងសុខាភិបាល និងសេវាមនុស្សជាតិក្រុងឡុងប៊ីឆ គឺជាដែនសមត្ថកិច្ចយុត្តាធិការមួយ នៃដែនសមត្ថកិច្ចយុត្តាធិការមួយចំនួនតូចប៉ុណ្ណោះនៅក្នុងរដ្ឋ ដែលមានលទ្ធភាពទទួលបាននូវមន្ទីរពេទ្យចល័ត។

គ្លីនិកប៉ាន់ប្រមាណឆាប់រហ័សដោយដើរឆ្លងកាត់ និងបើកនាអាទិត្យក្រោយ នៅឯមហាវិទ្យាល័យឡុងប៊ីឆស៊ីធីខូលេឆ Long Beach City College Pacific Coast Campus, និងផ្តល់ជំនួយវេជ្ជសាស្ត្រដល់ជនណា ដែលមានអារម្មណ៍ជំនះចិត្ត ឬដោយខានមិនបាន ត្រូវទៅពិនិត្យជំងឺនៅឯបន្ទប់សង្គ្រោះបន្ទាន់ សំរាប់លក្ខ័ណ្ឌជំងឺរបស់ពួកគេ។ មិនមានការផ្តល់នូវការព្យាបាល, ថត X-rays ឬបំពេញឡើងវិញនូវឱសថនៅទីតាំងនោះឡើយ ប៉ុន្តែនិងផ្តល់នូវការប៉ាន់ប្រមាណវេជ្ជសាស្ត្រ ហើយនិងចេញបន្តរជាថ្មី និងចេញនូវវេជ្ជបញ្ជាឱសថ សំរាប់ជនណាដែលត្រូវការ នូវការថែទាំបញ្ហាសុខភាពតាមទំលាប់របស់ពួកគេ។ សូមធ្វើការណែនាំដល់អ្នកដែលត្រូវការចេញបន្តរជាថ្មី នូវវេជ្ជបញ្ជាឱសថ អោយយកមកជាមួយនូវបញ្ជីនៃឱសថបច្ចុប្បន្នទាំងឡាយរបស់ពួកគេ ឬសំបកដបថ្នាំ ប្រសិនបើពួកគេមានវា។ អ្នកដែលក្អក គ្រុនមានកន្ទួលឈឺក ឬមានរោគសញ្ញាដូចជាផ្តាសាយកំរឹតមធ្យម និងត្រូវធ្វើការវាយតំលៃនៅកន្លែងដាច់ដោយឡែកមួយ ហើយដោយផ្អែកលើការប៉ាន់ប្រមាណទៅលើស្ថានភាពវេជ្ជសាស្ត្ររបស់ពួកគេ អាចនិងត្រូវបញ្ជូនទៅធ្វើតេស្តរកជំងឺ COVID-19។ ចាប់ពីថ្ងៃច័ន្ទ ទី៦ ខែមេសា គ្លីនិកនិងដំណើរការ ពីម៉ោង១០:០០ព្រឹក រហូតដល់ម៉ោង០៦:០០ល្ងាច ៧ថ្ងៃក្នុងមួយអាទិត្យ រហូតដល់ថ្ងៃ ជូនដំណឹងបន្ថែមទៀត។ ការចតរថយន្ត អាចរកបាននៅកន្លែងចតរថយន្ត ក្នុងបរិវេណសាលា ជិតផ្លូវ Orange Ave., ខាងជើងផ្លូវ Pacific Coast Highway។ ផ្លាកសញ្ញា និងត្រូវប្រគល់ទៅអោយឯកត្តបុគ្គលដោយផ្ទាល់ ដើម្បីធ្វើដំណើរទៅកាន់តង់គ្លីនិក។

លើសពីនេះទៀត ស៊ីធីបានបង្កើតផងដែរ នូវមន្ទីរពេទ្យតាមទីធ្លាកីឡាបណ្តោះអាសន្នមួយ នៅក្នុងទីធ្លាកីឡា Long Beach Sports Arena, ដោយមានភស្តុភារផ្គត់ផ្គង់វេជ្ជសាស្ត្រនានា និងមានប្រហែល ១០០ គ្រែតូចៗ។ មន្ទីរពេទ្យតាមទីធ្លាកីឡា បានដាក់ពង្រាយរហូតមកទល់ថ្ងៃនេះ និងត្រៀមរួចជាស្រេចក្នុងការដាក់អោយដំណើរការ ប្រសិនបើមានតំរូវការ ដើម្បីបំបាត់នូវសម្ពាធពីមន្ទីរពេទ្យតំបន់។

ទាំងមន្ទីរពេទ្យតាមទីធ្លាកីឡា និងទាំងគ្លីនិកប៉ាន់ប្រមាណឆាប់រហ័ស និងត្រូវដាក់អោយកាន់កិច្ចការងារដោយសមាជិកនៃកងបំរុងវេជ្ជសាស្ត្រក្រុងឡុងប៊ីឆ (Long Beach Medical Reserves Corps), ដែលរួមមាន អ្នកជំនាញវេជ្ជសាស្ត្រស្ម័គ្រចិត្តមកពីសហគមន៍ រួមមានទាំងវេជ្ជបណ្ឌិត គិលានុបដ្ឋាយិកា ជំនួយការវេជ្ជសាស្ត្រ និងគ្រូពេទ្យជំនាញអនុវត្តគិលានុបដ្ឋាយិកា ជាច្រើនអ្នក។

ចាប់ពីថ្ងៃច័ន្ទ ទី១ ខែមេសា ឆ្នាំ២០២០ ដៃគូរសហគមន៍ថែទាំសុខភាព រួមមាន College Medical Center, Lakewood Regional Medical Center, Long Beach Memorial Medical Center, Los Alamitos Medical Center, Miller Children’s and Women’s Hospital, និង St. Mary Medical Center, អាចកាន់កិច្ចការបានច្រើនជាង ១,៤០០ គ្រែ។ ជាលទ្ធផលនៃវិធានការណ៍រៀបចំដ៏ទូលំទូលាយនេះ ភាពជាដៃគូរថែទាំសុខភាព ឥឡូវនេះអាចផ្តល់ជំនួយគាំទ្រដល់ការហូរចូលយ៉ាងច្រើន នៃចំនួនច្រើនជាង ៤០០ គ្រែបន្ថែមទៀត នៅឯទីកន្លែងរបស់ពួកគេ ជារួម។ តួលេខទាំងនេះ គឺផ្អែកលើការផ្គត់ផ្គង់បុគ្គលិកដែលមាននាពេលបច្ចុប្បន្ន ហើយអាចនិងផ្លាស់ប្តូររៀងរាល់ពេល អាស្រ័យលើការវិវត្តនៃវិបត្តិសុខភាព។ ការដាក់អោយដំណើរការនូវមន្ទីរពេទ្យតាមទីធ្លាកីឡា និងផ្តល់នូវ ១០០ គ្រែបន្ថែមទៀត ក្នុងការបំពេញបន្ថែម ទៅលើតំរូវការថែទាំសុខភាពបន្ទាន់នៅក្នុងស៊ីធី។

[Type here]

ស៊ីធីឡុងប៊ីឆបន្តធ្វើការ ដើម្បីបង្កើតនូវទីតាំងធ្វើតេស្ត(ច្រើនកន្លែង) ដោយការបើកឆ្លងកាត់ ឬ drive-thru នៅក្នុងស៊ីធី។ ពត៌មានបន្ថែមទៀត និងត្រូវផ្តល់អោយនៅអាទិត្យក្រោយ។

សំរាប់ពត៌មានថ្មីៗបំផុតស្តីអំពីជំងឺ COVID-19, ជាមួយនិងពត៌មានពិស្តារទាំងឡាយ ដែលសាលាក្រុងឡុងប៊ីឆកំពុងតែធ្វើ ដើម្បីរក្សានូវប្រជាពលរដ្ឋទាំងអស់របស់ខ្លួន អោយមានសុវត្ថិភាព, ទស្សនា www.longbeach.gov/COVID19 និងតាមមើល @LongBeachCity លើ Facebook, Twitter និង Instagram.

សំរាប់ពត៌មាន, រូបភាព, វីឌីអូ និងសេចក្តីប្រកាសនានាបន្ថែមទៀត នៃអ្វីដែលកំពុងកើតឡើងក្នុងក្រុងឡុងប៊ីឆ តាមមើលពួកយើង លើ Facebook, Twitter, Instagram និង YouTube.